01066625

E329/7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 02 / 2015
ម៉ោង (Time/Heure) : 15:25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Claudia FENZ** |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើកទីបួន នៅលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Nicholas KOUMJIAN

**<u>ជនជាប់ចោទ</u>**
នួន ជា
ខៀវ សំផន

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ពេជ អង្គ
Marie GIRAUD

**<u>មេធាវីជនជាប់ចោទ</u>**
សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. ប្រវត្តិនីតិវិធី

១. អនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង តាមឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងអ្នកជំនាញពីររូបគឺ វេជ្ជបណ្ឌិត CHAN Kin Ming និងវេជ្ជបណ្ឌិត ហួត លីនណា ("អ្នកជំនាញ") ដើម្បីពិនិត្យវាយតម្លៃជនជាប់ចោទទាំងពីររូប និងធ្វើរបាយការណ៍ស្ដីពីសម្បទារបស់ពួកគេក្នុងការចូលរួមសវនាការ[1]។ បន្ទាប់ពីបានពិនិត្យវាយតម្លៃជនជាប់ចោទទៅតាមដីកាបង្គាប់របស់អង្គជំនុំជម្រះរួចហើយ អ្នកជំនាញបានដាក់របាយការណ៍របស់ខ្លួននៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥[2]។ នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ បន្ទាប់ពីមានសំណើពីអង្គជំនុំជម្រះ អ្នកជំនាញបានផ្ដល់នូវយោបល់បន្ថែមទៀតស្ដីពីរយៈពេលសវនាការក្នុងមួយថ្ងៃៗដែលសមរម្យសម្រាប់ជនជាប់ចោទ និងបានលើកឡើងនូវផលប៉ះពាល់នៃបញ្ហាសុខភាពជាក់លាក់នាពេលថ្មីៗ ដែល ខៀវ សំផន ជួបប្រទះក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសវនាការ[3]។ ចៅក្រម និងភាគីមានឱកាសក្នុងការសួរដេញដោលអ្នកជំនាញ ទៅលើរបាយការណ៍ និងមតិយោបល់របស់ពួកគេ នៅក្នុងសវនាការជាសាធារណៈនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥។

---

[1] ដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃលើសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ ("ដីកា") ឯកសារ E329 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥។

[2] របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ៖ នួន ជា ("របាយការណ៍ស្ដីពី នួន ជា") ឯកសារ E329/4 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥។ របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ៖ ខៀវ សំផន ឯកសារ E329/5 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥។

[3] សារអេឡិចត្រូនិកពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង ក្នុងការឆ្លើយតបទៅនឹងឯកសារ E329/6 ("សារអេឡិចត្រូនិកលើកទី១ របស់អ្នកជំនាញ") ឯកសារ E329/6/1 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។ សារអេឡិចត្រូនិកលើកទី២ ពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង ក្នុងការឆ្លើយតបទៅនឹងឯកសារ E329/6 ("សារអេឡិចត្រូនិកលើកទី២ របស់អ្នកជំនាញ") ឯកសារ E329/6/2 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។ អង្គជំនុំជម្រះបានទទួលពីមេធាវីការពារក្ដី ខៀវ សំផន ដែលបានស្នើសុំឱ្យចាត់ថ្នាក់ឡើងវិញនូវសារអេឡិចត្រូនិកលើកទី១ របស់អ្នកជំនាញ ពីសម្ងាត់ ទៅជាសម្ងាត់បំផុត និងសុំឱ្យសារអេឡិចត្រូនិកលើកទី២ របស់អ្នកជំនាញ ស្ថិតនៅក្នុងការចាត់ថ្នាក់ជាសម្ងាត់បំផុតដដែល។ មេធាវីការពារក្ដី ខៀវ សំផន បានលើកឡើងថា សវនាការជាសាធារណៈស្ដីពីសុខភាពរបស់ ខៀវ សំផន ផ្ដល់នូវព័ត៌មានលំអិត និងពេញលេញស្ដីពីសុខភាពរបស់ ខៀវ សំផន។ ប្រតិចារិកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៥៦ ដល់ ៥៧ (ភាសាអង់គ្លេស)។ ដោយពិចារណាឃើញថា អ្នកជំនាញបានពិភាក្សាពីព័ត៌មានដែលមាននៅក្នុងសារអេឡិចត្រូនិកទាំងពីរជាសាធារណៈក្នុងអំឡុងពេលស្ដាប់សវនាការស្ដីពីសម្បទារបស់ជនជាប់ចោទនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ការចាត់ថ្នាក់សារអេឡិចត្រូនិកលើកទី១ របស់អ្នកជំនាញ និងសារអេឡិចត្រូនិករបស់អ្នកជំនាញជាសម្ងាត់បំផុត មិនបានបម្រើផលប្រយោជន៍សាធារណៈទេ។ ហេតុនេះ អង្គជំនុំជម្រះនឹងចាត់ថ្នាក់ជាថ្មីចំពោះសារអេឡិចត្រូនិកទាំងពីរលើករបស់អ្នកជំនាញ ជាសាធារណៈ។

២. នៅក្នុងសវនាការថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ អ្នកជំនាញបានបំភ្លឺពីសេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់ពួកគេ។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឱ្យអ្នកជំនាញបំភ្លឺពីសេចក្តីសន្និដ្ឋានរបស់ពួកគេនៅក្នុងសារអេឡិចត្រូនិកលើកទី១ ដែលថា សវនាការរយៈពេលបួនថ្ងៃក្នុងមួយសប្តាហ៍ជាការសមស្របសម្រាប់ជនជាប់ចោទ។ អ្នកជំនាញក៏បានពិភាក្សាផងដែរ ពីលទ្ធផលនៃការពិនិត្យទៅលើ ខៀវ សំផន ដោយអង្គភាពវេជ្ជសាស្ត្រនៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានផ្អាកសវនាការមុនពេលកំណត់ដោយមូលហេតុ ខៀវ សំផន មានបញ្ហាសុខភាព។ សហព្រះរាជអាជ្ញាអន្តរជាតិ មេធាវីការពារក្តី ខៀវ សំផន មេធាវីការពារក្តី នួន ជា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏បានសាកសួរដេញដោលទៅលើអ្នកជំនាញនាពេលសវនាការនោះដែរ។

៣. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចចំនួនបីដងដោយឡែកពីគ្នាថា នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ[4]។ ដើម្បីសម្រេចថាតើ គាត់នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ឬយ៉ាងណានោះ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យអ្នកជំនាញរាយការណ៍ពីព័ត៌មានដែលអាចជួយឱ្យអង្គជំនុំជម្រះសម្រេចពីសម្បទារបស់ជនជាប់ចោទ អនុលោមទៅតាមលក្ខណៈវិនិច្ឆ័យដែលមានរៀបរាប់នៅក្នុងសាលដីកាលើបណ្តឹងសាទុក្ខក្នុង *រឿងក្តី Strugar*[5]។

## ២. ការពិនិត្យវាយតម្លៃដោយអ្នកជំនាញ

៤. អ្នកជំនាញបានពិនិត្យវាយតម្លៃជនជាប់ចោទ នួន ជា នៅថ្ងៃទី ១៩ និង ទី ២០ ខែ មករា ឆ្នាំ ២០១៥ និងបានពិនិត្យទៅលើរបាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍របស់គ្រូពេទ្យប្រចាំការនៅ

[4] សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E301/11 ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។ សេចក្តីសម្រេចលើកទីពីរ លើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E265/5 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣។ សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ឯកសារ E115/3 ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[5] ដីកា កថាខណ្ឌ ៧ ដោយដកស្រង់ចេញពី *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Strugar* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY សំណុំរឿងលេខ IT-01-42-A សាលដីកា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ (*"រឿងក្តី Strugar"*) កថាខណ្ឌ ៥៥ (ភាសាអង់គ្លេស)។

មន្ទីរឃុំឃាំង អ.វ.ត.ក និង មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅទីក្រុងភ្នំពេញ[6]។ អ្នកជំនាញបានរាយការណ៍ថា នួន ជា ធ្លាប់មានជំងឺរុំារ៉ៃនានាជាច្រើន[7] តែបានជាសះស្បើយទាំងស្រុងពីជំងឺរលាកទងសួតកម្រិតធ្ងន់នៅក្នុងឆ្នាំ ២០១៣[8]។ សម្ពាធឈាម សំឡេងបេះដូង សភាពស្តេកស្តាំង ការដកដង្ហើម ចលនាសាច់ដុំ និងការស្តាប់សំឡេងរបស់គាត់មានសភាពជាធម្មតាទេ[9]។

៥. នួន ជា បានត្អូញត្អែរពីការឈឺខ្នងចាប់ពីឆ្នាំ ២០០៧ មក[10]។ ក្រុមវេជ្ជបណ្ឌិតដែលព្យាបាលគាត់នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាយការណ៍ថា អាការៈឈឺចង្កេះរបស់គាត់បានធូរស្រាលហើយ ហើយថា នាពេលនេះ គាត់អាចក្រោកអង្គុយបាន ប៉ុន្តែមិនបានយូរឡើយ និងអាចដើរដោយខ្លួនឯងបានដោយប្រើដែកច្រត់[11]។ ទោះជាយ៉ាងណា ក្រុមវេជ្ជបណ្ឌិតដែលព្យាបាលគាត់ក៏រាយការណ៍ថា នាពេលនេះ នួន ជា ដើរយឺតជាងមុន[12]។ អ្នកជំនាញបានសន្និដ្ឋានថា អវយវៈរបស់គាត់កន្ត្រាក់ធម្មតា[13]។ នួន ជា បានរៀបរាប់ពីការឈឺចុកចាប់ដែលអាចទ្រាំបាន នៅពេលធ្វើចលនា តែគាត់បាននិយាយថា ការឈឺចុកចាប់នោះបានបាត់ទៅវិញនៅពេលគាត់សម្រួលជំហរចុងក្រោយរួចហើយ[14]។ អ្នកជំនាញយល់ថា ការឈឺចុកចាប់នៅឆ្អឹងខ្នង ជង្គង់ និងសន្លាក់ត្រគាកគឺស្របទៅតាមវ័យរបស់គាត់[15]។

៦. នួន ជា ក៏បានត្អូញត្អែរប្រាប់ដល់គ្រូពេទ្យដែលព្យាបាលនៅមន្ទីរឃុំឃាំងដែរអំពីអាការៈវិលមុខ ប៉ុន្តែអាការៈនេះមិនកើតឡើងញឹកញាប់ទេ ហើយកើតឡើងម្តងៗតែមួយរយៈខ្លីប៉ុណ្ណោះ[16]។ អ្នក

[6] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៧, ១០។ ប្រតិចារិកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៩ (ភាសាអង់គ្លេស)។

[7] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៦។

[8] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៤។ ប្រតិចារិកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៦ (ភាសាអង់គ្លេស)។

[9] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៤។ ប្រតិចារិកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១១ (ភាសាអង់គ្លេស)។

[10] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៦។ ប្រតិចារិកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៨ (ភាសាអង់គ្លេស)។

[11] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៧។ ប្រតិចារិកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១០-១២ (ភាសាអង់គ្លេស)។

[12] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៧។

[13] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៤។ ប្រតិចារិកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១១ (ភាសាអង់គ្លេស)។

[14] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៤។ ប្រតិចារិកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១១ (ភាសាអង់គ្លេស)។

[15] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៤។

[16] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៨។ ប្រតិចារិកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១២ (ភាសាអង់គ្លេស)។

ជំនាញយល់ថា អាការៈវិលមុខគឺជាប់ពាក់ព័ន្ធទៅនឹងបញ្ហាប្រព័ន្ធប្រសាទផ្នែកត្រចៀកគាត់ តែបាន សន្និដ្ឋានថា ប្រការនេះមិនប៉ះពាល់ដល់សម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួម សវនាការទេ[17]។ អ្នកជំនាញបានសន្និដ្ឋានថា នួន ជា មានសុខភាពល្អ បើគិតទៅតាមអាយុ និង ស្ថានភាពជំងឺរ៉ាំរ៉ៃមួយចំនួនរបស់គាត់[18]។

៧. ក្នុងអំឡុងពេលអ្នកជំនាញសម្ភាសរូបគាត់ នួន ជា មានស្មារតីល្អ អាចអង្គុយបានដោយគេជួយ គ្រាហ៍ និងអាចតោងទប់លើដែកច្រត់ដោយគ្មានបញ្ហាអ្វីឡើយ[19]។ គាត់មានសុខភាពប្រសើរ និង ស្មារតីល្អ ញញឹមស្រស់ស្រាយ និងមានក្រសែភ្នែកប្រាស្រ័យទាក់ទងគ្នាល្អជាមួយអ្នកជំនាញ[20]។ នួន ជា និយាយឮៗ និងច្បាស់លាស់ និងបានចងចាំថា គាត់ធ្លាប់ជួបជាមួយអ្នកជំនាញកាលពីមុន ទោះបីគាត់មិនអាចនឹកឃើញឈ្មោះរបស់ពួកគេក៏ដោយ[21]។ នួន ជា មានអារម្មណ៍ថា ភ្នែករបស់ គាត់មើលមិនសូវឃើញច្បាស់ទេ តែគាត់ស្តាប់ព័ត៌មានតាមវិទ្យុវិញ និងអាចមើលគំនូសភូគោល និងផែនទីពិភពលោក ដោយអាចរកឃើញប្រទេសនានាដែលបានលើកឡើងក្នុងព័ត៌មានដែលបាន ផ្សាយនោះបាន[22]។

៨. ក្រុមវេជ្ជបណ្ឌិតដែលព្យាបាល នួន ជា នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលបានស្គាល់គាត់អស់ រយៈពេលប្រហែល ៤ ឆ្នាំមកហើយ កត់សម្គាល់ថា ការចងចាំរបស់គាត់មិនមានបញ្ហាទេ ហើយ ថា មើលទៅគាត់ដូចមានការផ្តល់អារម្មណ៍បានធម្មតា និង មានអារម្មណ៍ធម្មតា[23]។ បុគ្គលិកមន្ទីរ ឃុំឃាំងមិនបានសម្គាល់ឃើញថា នួន ជា មានបញ្ហាចំពោះការចងចាំទេ ហើយបានរៀបរាប់ថា គាត់នៅចាំពួកគេទាំងអស់ និងមិនបានវង្វេងនៅក្នុងបរិវេណមន្ទីរឃុំឃាំងទេ[24]។ អ្នកជំនាញបាន សន្និដ្ឋានថា នួន ជា អាចផ្តល់អារម្មណ៍ក្នុងអំឡុងពេលនៃការសម្ភាសន៍ទាំងពីរលើក រយៈពេល ៦០

---

[17] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៧។

[18] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៤០។

[19] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១០។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១០ (ភាសាអង់គ្លេស)។

[20] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៤។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១០ (ភាសាអង់គ្លេស)។

[21] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១១។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១០ (ភាសាអង់គ្លេស)។

[22] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៣។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១១-១២ (ភាសាអង់គ្លេស)។

[23] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ១៩។

[24] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២០។

នាទីម្តង និង ៤០ នាទីម្តងទៀត និងបានកត់សម្គាល់ថា គាត់មិនបង្ហាញពីការនឿយហត់ មានស្មារតីល្អ និងឆ្លើយតបបានច្បាស់លាស់ទៅនឹងសំណួរនានាដែលបានសួរ[25]។ អ្នកជំនាញក៏បានរកឃើញភស្តុតាងល្អបង្ហាញអំពីការរក្សាបាននូវការចងចាំរយៈពេលវែងរបស់ នួន ជា ដែរ៖ គាត់បានផ្តល់ព័ត៌មានលំអិតអំពីឪពុកម្តាយ និងការអប់រំរបស់គាត់ ដែលស៊ីសង្វាក់ទៅនឹងចម្លើយនានាដែលគាត់បានផ្តល់ឱ្យអ្នកជំនាញនៅឆ្នាំ ២០១៤[26]។ នួន ជា ក៏បានផ្តល់ព័ត៌មានអំពីតួនាទីរបស់គាត់ក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែរ[27]។ នួន ជា ក៏ទទួលបានពិន្ទុធម្មតាដែរ ចំពោះការត្រួតពិនិត្យស្ថានភាពផ្លូវចិត្តដោយអ្នកជំនាញ[28]។ អ្នកជំនាញយល់ឃើញថា សភាពផ្លូវចិត្តរបស់ នួន ជា មានលក្ខណៈធម្មតា[29]។ អ្នកជំនាញក៏បានសន្និដ្ឋានជាពិសេសថា នួន ជា មានសមត្ថភាពចាំបាច់នានាដែលបានកំណត់នៅក្នុង *រឿងក្តី Strugar*[30]។

៩. អ្នកជំនាញកត់សម្គាល់ថា នួន ជា មានអាយុ ៨៨ ឆ្នាំ មានសភាពទ្រុឌទ្រោម ហើយប្រឈមនឹងការថមថយកម្លាំងកាយ ដោយសារការធ្លាក់ចុះយ៉ាងលឿននៃមុខងារផ្នែកផ្លូវកាយ[31]។ ពួកគេក៏បានសន្និដ្ឋានទៀតថា ទំនងជាថា ការចងចាំ និងមុខងារផ្នែកបញ្ញាស្មារតីរបស់ នួន ជា អាចនឹងមានការធ្លាក់ចុះបន្តិចម្តងៗទៅតាមវ័យរបស់គាត់[32]។ ហេតុដូច្នេះហើយ អ្នកជំនាញផ្តល់អនុសាសន៍ឱ្យមានការពិនិត្យឡើងវិញជាទៀងទាត់ទៅលើមុខងារផ្នែកបញ្ញាស្មារតីរបស់គាត់[33]។ នៅឯសវនាការ អ្នកជំនាញបានផ្តល់អនុសាសន៍ឱ្យធ្វើការពិនិត្យជាទៀងរាល់ខែ ឬបីខែម្តង[34]។

---

[25] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២១។

[26] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២៣។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៣ (ភាសាអង់គ្លេស)។

[27] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២៤។

[28] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២៥។

[29] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២៦។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៣ (ភាសាអង់គ្លេស)។

[30] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ២៩ ដល់ ៣៦, ៤៥។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៣ (ភាសាអង់គ្លេស)។

[31] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៦, ១៥។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៤៧ (ភាសាអង់គ្លេស)។

[32] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៤៦។

[33] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ៤៦។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៩ ដល់ ២១ (ភាសាអង់គ្លេស)។

[34] ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២២ (ភាសាអង់គ្លេស)។

១០. គ្មានភាគីណាមួយ បានជំទាស់ទៅលើរបាយការណ៍របស់អ្នកជំនាញឡើយ។

## ៣. ច្បាប់អនុវត្ត

១១. ដើម្បីកំណត់ថា មានសម្បទាក្នុងការចូលរួមសវនាការ ជនជាប់ចោទត្រូវមានលទ្ធភាពក្នុងការចូលរួមសវនាការប្រកបដោយអត្ថន័យ ដែលមានន័យថា គាត់អាចអនុវត្តសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស នៅក្នុងកំរិតមួយដែលគាត់អាចចូលរួមបានដោយមានប្រសិទ្ធភាព ហើយយល់ដឹងពីផ្នែកសំខាន់ៗនៃកិច្ចដំណើការនីតិវិធី[35]។

## ៤. សម្អាងហេតុ

១២. ដើម្បីវាយតម្លៃថាតើ ជនជាប់ចោទមានសម្បទាក្នុងការចូលរួមសវនាការ ឬយ៉ាងណានោះ អង្គជំនុំជម្រះពិចារណាទៅលើកត្តាទាំងអស់ដែលពាក់ព័ន្ធ រួមមានភស្តុតាងពីអ្នកជំនាញ ការសង្កេតរបស់អង្គជំនុំជម្រះផ្ទាល់ ផលប៉ះពាល់ទៅលើស្ថានភាពសុខភាពរបស់ជនជាប់ចោទ ភាពរកបាននៃវិធានការអនុវត្តដើម្បីជួយសម្រួលផលប៉ះពាល់នៃការចុះខ្សោយ ហើយថា ជនជាប់ចោទត្រូវបានតំណាង និងផ្តល់ការប្រឹក្សាយោបល់ពីក្រុមមេធាវីដែលមានសមត្ថភាព។

១៣. បន្ទាប់ពីបានពិនិត្យមើលទៅលើរបាយការណ៍ស្តីពី នួន ជា និងភស្តុតាងដែលផ្តល់ដោយអ្នកជំនាញនៅក្នុងសវនាការថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ រួចមក អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នួន ជា នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហើយនាពេលថ្មីៗនេះមិនបានទទួលរងនូវការចុះខ្សោយផ្នែកស្មារតី ឬផ្លូវកាយ ដែលរារាំងគាត់មិនឱ្យបន្តចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសម្រាប់សំណុំរឿង ០០២/០២ ទេ។

១៤. ជាងនេះទៀត នៅក្នុងសារអេឡិចត្រូនិកលើកទី១ របស់អ្នកជំនាញ អ្នកជំនាញបានអះអាងថា នួន ជា អាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការបួនថ្ងៃក្នុងមួយសប្តាហ៍បាន[36]។ ដោយផ្អែកលើកង្វល់នានាផ្នែកសុខភាពរបស់ ខៀវ សំផន អ្នកជំនាញបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគួរតែកែសម្រួលកាលវិភាគសវនាការរបស់ខ្លួន ដើម្បីបញ្ចូលការឈប់សម្រាកពីរម៉ោងសម្រាប់

[35] រឿងក្តី *Strugar* កថាខណ្ឌ ៥៥។

[36] សារអេឡិចត្រូនិករបស់អ្នកជំនាញលើកទី១ ទំព័រ ២។

អាហារថ្ងៃត្រង់ ដើម្បីអាចសម្រាកពេលថ្ងៃត្រង់បានយូរ[37]។ ដូចដែលបានប្រកាសក្នុងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះកាលពីថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ រួចមកហើយ គឺថា អង្គជំនុំជម្រះសាលាដំបូងនឹងដំណើរការសវនាការរៀងរាល់ថ្ងៃពីម៉ោង ៩:០០ ព្រឹក រហូតដល់ម៉ោង ១១:៣០ ព្រឹក និងបន្តពីម៉ោង ១:៣០ រសៀល រហូតដល់ម៉ោង ៤:០០ រសៀល ជាទូទៅពីថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បតិ៍[38]។

១៥. អង្គជំនុំជម្រះនឹងបន្តចាត់វិធានអនុវត្តផ្សេងៗទៀត ដូចជា អនុញ្ញាតឱ្យជនជាប់ចោទចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាមមធ្យោបាយសោតទស្សន៍ពីបន្ទប់ឃុំខ្លួន ស្ថិតនៅខាងក្រោមសាលសវនាការ អនុលោមតាមវិធាន ៨១(៥) នៃវិធានផ្ទៃក្នុង ក្នុងករណីចាំបាច់។ អង្គជំនុំជម្រះសន្និដ្ឋានថា វិធានការទាំងនេះនឹងជួយសម្រួលគ្រប់គ្រាន់ដល់ភាពចុះខ្សោយផ្នែកលើស្ថានភាពសុខភាពរបស់ជនជាប់-ចោទ នួន ជា។ នាពេលអនាគត ក្នុងករណីសមស្រប អង្គជំនុំជម្រះក៏នឹងចេញដីកាសម្រេចអនុវត្តទៅតាមអនុសាសន៍របស់អ្នកជំនាញ ដើម្បីបន្តការព្យាបាលដោយចលនាសម្រាប់ នួន ជា ការពិនិត្យទៅលើមុខងារសតិបញ្ញាស្មារតីរបស់គាត់ និងការជួយសម្រួលដែលនឹងអនុញ្ញាតឱ្យគាត់អង្គុយស្តាប់ក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល បន្ទាប់ពីបានកំណត់នូវវិធីសាស្ត្រសមស្របបំផុតក្នុងការធ្វើបែបនេះ បើទោះបីជាគាត់មានបញ្ហាឈឺខ្នងក៏ដោយ។

**សម្រាប់សំអាងដូចដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង៖**

**បញ្ជាក់** ថា ជនជាប់ចោទ នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។

ភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. * E.T.C.

**និល ណុន**

[37] ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៣២ ដល់ ៣៣, ៤៥ ដល់ ៤៧ (ភាសាអង់គ្លេស)។ ប្រតិចារឹកថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២៥ ដល់ ២៦ (ភាសាអង់គ្លេស)។

[38] ប្រតិចារឹកថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២៦ (ភាសាអង់គ្លេស)។